ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ២២ សសរ

## ស្តីពីការបង្កើតគណៈកម្មការពិគ្រោះការងារ ដើម្បីពង្រីកកិច្ច សហប្រតិបត្តិការរវាងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដើម្បីរៀបចំកងកំលាំង ប្រដាប់អាវុធកម្ពុជា

* * *

### រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ សម្តេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា
- យោងតាមកិច្ចព្រមព្រៀងរវាង រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង អំពីកិច្ចសហប្រតិបត្តិការ បច្ចេកទេស ក្នុងវិស័យការពារ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៣

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការពិគ្រោះការងារ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងដើម្បីរៀបចំកងកំលាំងប្រដាប់អាវុធកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម ឧត្តមសេនីយ សក់ ស៊ុតសាខន ទីប្រឹក្សាអមសហប្រធាន នៃរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជាទទួលបន្ទុកកិច្ចការពារជាតិ ជាប្រធាន

២- ឯកឧត្តម ឧត្តមសេនីយឯក ទៀ បាញ់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៣- ឯកឧត្តម ឧត្តមសេនីយឯក ទា ចំរ៉ាត់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធាន

៤- ឯកឧត្តម ឧត្តមសេនីយឯក កែ គីមយ៉ាន នាយអគ្គសេនាធិការនៃ កងទ័ពជាតិ ជាអនុប្រធាន

៥- ឯកឧត្តម ស៊ុំ ម៉ានិត អនុរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៦- ឯកឧត្តម អ៊ុច គីមអន អនុរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិ ជាសមាជិក

៧- ឯកឧត្តម ឡាយ ព្រហ្មស្ត អនុរដ្ឋមន្ត្រីក្រសួងផែនការ ជាសមាជិក

៨- ឯកឧត្តម ខិត មុន្នី អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ ជាសមាជិក

៩- ឯកឧត្តម ឧត្តមសេនីយឯក ទន់ ចាយ អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ជាសមាជិក

១០- ឯកឧត្តម ចម ប្រសិទ្ធ អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ជាសមាជិក

១១- ឯកឧត្តម កាន់ ម៉ន អនុរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងការងារ ជាសមាជិក

១២- ឯកឧត្តម ឆាយ ថន អនុរដ្ឋមន្ត្រីក្រសួងអតីតយុទ្ធជន ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះ ស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់សហប្រធាន នៃ រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា និង ជាសហអគ្គមេបញ្ជាការ នៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា មានភារកិច្ចធ្វើការពិគ្រោះគ្នាដោយទៀងទាត់នៅក្នុងក្របខណ្ឌ នៃគណៈកម្មការរួមមួយ រវាងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា និង រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំង ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ រៀបចំកងកំលាំងប្រដាប់អាវុធកម្ពុជា តាមកិច្ចព្រមព្រៀង នៃភាគីទាំងពីរ និងរៀបចំទូរាល់គំរោងកិច្ចព្រមព្រៀង និង ការសំរបសំរួលបច្ចេកទេសជាទ្វេភាគីដោយឡែក ៗ និងកំណត់អោយក្របខ័ណ្ឌ និង បែបបទ នៃសកម្មភាពសហប្រតិបត្តិការ ដែលត្រូវអនុវត្តនៅលើ មូលដ្ឋាននៃគោលការណ៍ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀង ។

ប្រការ ៣ : ដោយផ្អែកលើការសំរបសំរួលបច្ចេកទេសជាទេភាគីដោយឡែក ៗ គណៈកម្មការនេះមានភារកិច្ចរៀបចំជាអនុគណៈកម្មការតាមទំហំការងារជាក់ស្តែង ដើម្បីធ្វើការងារទៅតាមជំនាញនិមួយ ៗ ។

ប្រការ ៤ : ទីកន្លែងប្រជុំការងារ ក្នុងគណៈកម្មការរួមធ្វើនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង

សន្តិសុខជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង ការងារ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអតីតយុទ្ធជន និង ឯកឧត្តម អស់លោកដែលមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

*****

ភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ២៣ សសរ

## ស្តីពីការបង្កើតគណៈកម្មការចម្រុះត្រួតពិនិត្យ

## សន្តិសុខនៅតាម ខេត្ត ក្រុង នានា

* * *

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំង រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងសារាចរលេខ ០២ សរ ស្តីពីរបៀបរៀបរយ និង សន្តិសុខសាធារណៈរបស់ រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៣
- តាមសំណើរបស់ឯកឧត្តម ឧត្តមសេនីយ ទីប្រឹក្សាអមសហប្រធាន នៃរដ្ឋាភិបាលជាតិ បណ្តោះអាសន្ន នៃកម្ពុជាទទួលបន្ទុកកិច្ចការ ការពារជាតិ